**នៅចំពោះមុខការិយាល័យនៃអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ____)

ភាគីដាក់ឯកសារ: អោ អាន

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៨

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 29-Aug-2018, 11:18
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ អ.ប.ជ: **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើបន្ទាន់សុំការកោសលុប និងការចាត់វិធានការបណ្ដោះអាសន្ន**

---

**ដាក់ដោយ៖**

**សហមេធាវីការពារក្ដី**

លោក មុំ លុឲ្យ

លោក Richard ROGERS

លោក Göran SLUITER

**ផ្ញើជូន៖**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន

ចៅក្រម Olivier BEAUVALLET

ចៅក្រម ន៍យ ថុល

ចៅក្រម Kang Jin BAIK

ចៅក្រម ហ៊ួត វុទ្ធី

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

1. តាមរយៈសហមេមធាវី (“*មេធាវីការពារក្តី*”) របស់គាត់ អោ អាន សូមដាក់សំណើបន្ទាន់នេះ ដោយអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ហៅថា “*វិធានផ្ទៃក្នុង*” និង “*អ.វ.ត.ក*”) មាត្រា ៣.១២ និងមាត្រា ៣.១៤ នៃសេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារនៅ អ.វ.ត.ក (“*សេចក្តីណែនាំស្តីពីការដាក់ឯកសារ*”) ព្រមទាំងមាត្រា ៩.១ មាត្រា ៩.២ និងមាត្រា ៩.៣ នៃសេចក្តីណែនាំអនុវត្តស្តីអំពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង (“*សេចក្តីណែនាំស្តីពីចំណាត់ប្រភេទឯកសារ*”)។ មេធាវីការពារក្តីសូមដាក់សំណើនេះជាភាសាអង់គ្លេសសិនតែប៉ុណ្ណោះ ចំណែកសំណៅបកប្រែជាភាសាខ្មែរនឹងដាក់ជូនក្នុងពេលឆាប់ៗនេះ។

2. សំណើនេះអាចទទួលយកបាន ពីព្រោះថា ក្នុងការចេញដីកាដំណោះស្រាយទាំងនេះ ការិយាល័យសហចៅក្រមស៊ើបអង្កេត (“*ក.ស.ច.ស*”) *ត្រូវបំពេញតួនាទីរបស់ខ្លួន (functus officio)*[1]។ ហេតុដូច្នេះ ទោះបីពុំមានបណ្តឹងឧទ្ធរណ៍នាពេលនេះ ហើយភាគីកំពុងរង់ចាំការបកប្រែដីកាដំណោះស្រាយទាំងនេះក្តី ក៏អង្គបុរេជំនុំជម្រះ (“*អ.ប.ជ*”) គឺជាអង្គជំនុំជម្រះតែមួយគត់ ដែលមេធាវីការពារក្តីអាចដាក់ជូនសំណើទាំងនេះបាន[2]។

3. មេធាវីការពារក្តីស្នើជាបន្ទាន់ឲ្យអង្គបុរេជំនុំជម្រះ៖ (១) កោសលុបអាសយដ្ឋានផ្ទាល់ខ្លួនរបស់ អោ អានចេញពីទំព័រ ៤០៩នៃ*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* (“ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ” [3] និង (២) បង្គាប់ឲ្យការិយាល័យកិច្ចការសាធារណៈដកជាបន្ទាន់នូវ*ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ដែលមិនទាន់កោសលុបចេញពីគេហទំព័ររបស់ អ.វ.ត.ក។

---

[1] សំណុំរឿង ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥០) *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)* ឯកសារ D308/3/1/20 ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ៣៣ ដែលបានភ្ជាប់ជាឧបសម្ព័ន្ធ ១។ សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* ឯកសារ D360 ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ១៩។

[2] ពេលវេលាកំណត់សម្រាប់ការដាក់បណ្តឹងឧទ្ធរណ៍ មិនចាប់ផ្តើមរាប់នៅឡើយទេ លុះត្រាណាតែដីកាដំណោះស្រាយទាំងនេះត្រូវបានចេញយ៉ាងហោចណាស់ជាពីរភាសាសិនក្នុងចំណោមភាសាផ្លូវការរបស់តុលាការនេះ។ មាត្រា ២.២ និងមាត្រា ៨.៥ នៃ*សេចក្តីណែនាំស្តីពីការដាក់ឯកសារ*។

[3] សំណៅកោសលុបបានផ្តល់ជូននៅក្នុង**ឧបសម្ព័ន្ធ ក**។

4. ការបោះពុម្ពផ្សាយព័ត៌មានផ្ទាល់ខ្លួន ដូចជាអាសយដ្ឋានរបស់ អោ អាន ពុំផ្តល់ផលប្រយោជន៍សាធារណៈ ពុំចាំបាច់ និងប៉ះពាល់ដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធី និងពុំបានជួយគាំទ្រដល់ផលប្រយោជន៍យុត្តិធម៌ ឬកេរ្តិ៍ដំណែលរបស់ អ.វ.ត.ក ឬគោលបំណងផ្នែកអប់រំរបស់ អ.វ.ត.ក ទាល់តែសោះ។ ផ្ទុយទៅវិញ ការបោះពុម្ពផ្សាយនេះ រំលោភលើសិទ្ធិឯកជនរបស់ អោ អាន[4] (និងគ្រួសារគាត់) និងការសន្មតជាមុនថាគ្មានទោស[5] ហើយវាអាចនាំឲ្យមានការរុកគួនរំខានពីសំណាក់ប្រព័ន្ធផ្សព្វផ្សាយសំខាន់ៗ ឬផ្តល់នូវផលអាក្រក់ជាងនេះទៀតផង។ ទោះបីជាអាសយដ្ឋានរបស់ អោ អាន ធ្លាប់ ឬមិនធ្លាប់ត្រូវបានអ្នកសារព័ត៌មានបង្ហាញឲ្យដឹងពីមុនមកក្តី ក៏ចៅក្រមទាំងអស់នៃ អ.វ.ត.ក មានកាតព្វកិច្ច និងការទទួលខុសត្រូវក្នុងការធានាការពារដល់សិទ្ធិជាសារវន្តរបស់ អោ អាន និងភាពសម្ងាត់នៃកិច្ចដំណើរការនីតិវិធី។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពុំបានថ្លឹងថ្លែងតុល្យភាពរវាងសិទ្ធិរបស់សាធារណជនក្នុងការទទួលបានព័ត៌មាន ការរក្សាការសម្ងាត់នៃកិច្ចស៊ើបសួរ និងសិទ្ធិរបស់ អោ អាន ឡើយ។ មេធាវីការពារក្តីស្នើឲ្យអង្គបុរេជំនុំជម្រះ ចាត់ការជាបន្ទាន់ ដើម្បីកែតម្រូវកំហុសនេះ។

5. ក្នុងការគាំទ្រលើសំណើបន្ទាន់នេះ មេធាវីការពារក្តីសូមចង្អុលបង្ហាញថា នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទាំងឡាយ ជាពិសេសប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដែលពាក់ព័ន្ធបំផុតនឹង អ.វ.ត.ក ដូចជាប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌកម្ពុជា និងបារាំង ឬក្នុងការអនុវត្តជាក់ស្តែង គឺពុំអនុញ្ញាតឲ្យបោះពុម្ពផ្សាយឯកសារសាធារណៈរបស់តុលាការ នៅមុនដំណាក់កាលជំនុំជម្រះ នូវអាសយដ្ឋានពេញលេញរបស់ជនសង្ស័យ ឬជនត្រូវចោទនោះឡើយ[6]។

6. លើសពីនេះទៀត មេធាវីការពារក្តីកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏បានផ្សព្វផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ដែលបានស្នើសុំវិធានការការពារ ហើយដែលត្រូវបានចាត់ទុកថាជាជនរងគ្រោះដោយអំពើហិង្សាផ្លូវភេទ និងយែនឌ័រ រួមទាំង ការរំលោភសេព

[4] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៤០។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៧។

[5] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣៨។ អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស មាត្រា ៦(២)។

[6] *សូមមើល ឧទា.* ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១២១។ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១១ ដែលបានភ្ជាប់ជាឧបសម្ពន្ធ ២។ ច្បាប់បារាំងស្តីពីសេរីភាពនៃសារព័ត៌មាន ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៨៨១ មាត្រា ៣៨ ដែលបានភ្ជាប់ជាឧបសម្ព័ន្ធ ៣។

សន្តុវៈ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំផង[7]។ ទោះបីមេធាវីការពារក្តី មិនមានសិទ្ធិស្នើឲ្យធ្វើការកោសលុប ក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ក៏មេធាវីការពារក្តីសូមលើកឡើងនូវកំហុសនេះជូនអង្គបុរេជំនុំជម្រះផងដែរ ដោយហេតុថា ការបោះពុម្ពផ្សាយព័ត៌មានបែបនេះ ត្រូវបានហាមឃាត់ដោយច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ព្រមទាំងយុត្តាធិការជាតិ និង អន្តរជាតិផ្សេងៗទៀត[8]។

7. វិធាន ២១(១) នៃវិធានផ្ទៃក្នុងចែងថា ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន "ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ..."។

8. អនុលោមតាមមាត្រា ៣.១២ និងមាត្រា ៣.១៤ នៃសេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារ ព្រមទាំងមាត្រា ៩.១ មាត្រា ៩.២ និងមាត្រា ៩.៣ នៃសេចក្តីណែនាំអនុវត្តស្តីអំពីចំណាត់ប្រភេទឯកសារ បន្ទាប់ពីបានទទួលសំណើរបស់ភាគីដាក់ឯកសាររួចមក អង្គបុរេជំនុំជម្រះ និងសហចៅក្រមស៊ើបអង្កេតអាចដាក់ចំណាត់ប្រភេទ និងចាត់ចំណាត់ប្រភេទឯកសារឡើងវិញ ដោយមានការកោសលុបដែលចាំបាច់។ មាត្រា ១.២ នៃសេចក្តីណែនាំអនុវត្តស្តីអំពីចំណាត់ប្រភេទឯកសារពន្យល់ថា គោលការណ៍នេះគឺផ្អែកលើ "តម្រូវការទាមទារឲ្យមានតុល្យភាពរវាងភាពសម្ងាត់នៃកិច្ចស៊ើបសួររបស់តុលាការ និងផ្នែកផ្សេងៗទៀតនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ ដែលមិនបើកចំហរដល់សាធារណជនជាមួយនឹងតម្រូវការដើម្បីធានាដល់តម្លាភាពនៃកិច្ចដំណើរការនីតិវិធីសាធារណៈ និងសម្រាប់គោលបំណងផ្នែកអប់រំ និងកេរ្តិ៍ដំណែល"។

9. ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា "ការធ្វើចំណាត់ថ្នាក់លើឯកសារត្រូវធ្វើឡើងដោយធ្វើយ៉ាងណាឲ្យមានតុល្យភាព រវាងតម្រូវការនៃការរក្សាការសម្ងាត់ និងតម្រូវ

---

7 [redacted]

8 *ឧទា.* លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ៦៨(១) និង(២)។ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ៣០៦ ដែលបានភ្ជាប់ជាឧបសម្ព័ន្ធ ៤។ សូមមើលផងដែរ *រដ្ឋអាជ្ញា តទល់នឹងជនជាប់ចោទ Dominic Ongwen សេចក្តីសម្រេចលើ "សំណើសុំរបស់រដ្ឋអាជ្ញាឲ្យចាត់វិធានការការពារពិសេសតាមផ្លូវលោការ* តុលាការ ICC សំណុំរឿង ០២/០៤-០១/១៥-៦-១២-កោសលុបរួច ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ១៦ ដែលបានភ្ជាប់ជាឧបសម្ព័ន្ធ ៥។

ការនៃតម្លាភាព ដែលកើតចេញពីគោលការណ៍ជាសារវន្ត ដែលគ្រប់គ្រងលើនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ដោយពិចារណាលើគោលបំណងរបស់តុលាការ ក្នុងការអប់រំ និងរក្សាកេរដំណែល”[9]។

10. ស្រដៀងគ្នាដែរ ក្នុងសំណុំរឿង ០០៤/០១ នៅពេលពិចារណាទៅលើការធ្វើចំណាត់ប្រភេទឡើងវិញ និងការកោសលុប*ដីកាដំណោះស្រាយ (សំអាងហេតុ)* អង្គបុរេជំនុំជម្រះ បានទទួលស្គាល់ថា ជាចាំបាច់ត្រូវតែ “ថ្លឹងថ្លែងផលប្រយោជន៍ខុសៗគ្នាដែលរងប៉ះពាល់ រួមទាំងផលប្រយោជន៍របស់ជនត្រូវចោទ និងជនរងគ្រោះ តម្លាភាពនៃដំណើរការនីតិវិធី ដូចមានចែងក្នុងវិធាន ២១(១) នៃវិធានផ្ទៃក្នុង និងផលប្រយោជន៍យុត្តិធម៌”[10]។

11. ក្នុងសំណុំរឿង ០០៤/០២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពុំបានថ្លឹងថ្លែងតុល្យភាពនេះឲ្យបានត្រឹមត្រូវនៅក្នុង*ដីកាដំណោះស្រាយ*របស់គាត់ទេ។ គាត់មានកំហុសចំពោះការបោះពុម្ពផ្សាយអាសយដ្ឋានរបស់ អោ អាន ដោយពុំបានពិចារណាអំពីសិទ្ធិឯកជនរបស់ អោ អាន ឬការរក្សាភាពសម្ងាត់នៃកិច្ចស៊ើបសួរនោះឡើយ។ ការបោះពុម្ពផ្សាយព័ត៌មានឯកជនបែបនេះ ពុំចាំបាច់ដើម្បីធានាដល់តម្លាភាព ឬរក្សាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីនោះទេ។ តាមពិត វាពុំមានផលប្រយោជន៍ជាសាធារណៈនោះទេ ហើយក៏ពុំបានជួយគាំទ្រដល់ផលប្រយោជន៍យុត្តិធម៌ណាមួយនោះដែរ។

12. ហេតុដូច្នេះ មេធាវីការពារក្តីសូមស្នើឲ្យអង្គបុរេជំនុំជម្រះ មេត្តា៖

ក. កោសលុបអាសយដ្ឋានរបស់ អោ អាន ចេញពីសំណៅសាធារណៈនៃ*ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ*(សំណៅកោសលុបមានផ្តល់ជូននៅក្នុង**ឧបសម្ព័ន្ធ ក**)។ និង

ខ. បង្គាប់ឲ្យការិយាល័យកិច្ចការសាធារណៈ ដកជាបន្ទាន់នូវ*ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ដែលមិនទាន់កោសលុបចេញពីគេហទំព័ររបស់ អ.វ.ត.ក។

---

[9] សំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក, *សេចក្តីសម្រេចលើគោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង* ឯកសារ F30/2 ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ កថាខណ្ឌ ៥ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ៦។

[10] សំណុំរឿង ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៤៩) *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើការកោសលុប ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សំអាងហេតុ)* ឯកសារ D309/2/1/7 ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ២៨ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ៧។

សូមដាក់ជូនដោយក្តីគោរព។

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៨

| | | |
|---|---|---|
| មុំ លុជ្ស | Richard ROGERS | Göran SLUITER |

**សហមេធាវីការពារក្តីរបស់លោក អោ អាន**